វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA

## ឯកសារស្រាវជ្រាវ

### គណៈកម្មការទី៨ នៃព្រឹទ្ធសភា

# ការធ្វើចំណាកស្រុក ការទប់ស្កាត់ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ

អ្នកស្រាវជ្រាវ៖ លោកស្រី រស់ បណ្ណែត
លោក គឹម សុធន
ជំនួយការ៖ លោកស្រី តុប ដាវី
លោក គង់ វណ្ណថេន
លោក សុខ សំណាង
ដឹកនាំ៖ លោក នូ កែវសុទ្ធា

ខែកក្កដា ឆ្នាំ២០១៧

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយ ដែលផ្តល់ការគាំទ្រដល់សភាកម្ពុជាតាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគតលើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗ ដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិកាសភា ក៏ប៉ុន្តែរាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពី ទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជាសភា ឬសមាជិកសមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះ មានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវនេះ ស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

© រក្សាសិទ្ធិ ឆ្នាំ ២០១៧ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)។

# មាតិកា


១. សេចក្តីផ្តើម ........ 1

២. ស្ថានភាពការធ្វើចំណាកស្រុកនៅក្នុងប្រទេសកម្ពុជា ........ 1

២.១ មូលហេតុនៃការធ្វើចំណាកស្រុក ........ 3

២.២ ផលប៉ះពាល់នៃការធ្វើចំណាកស្រុក ........ 4

២.៣ ក្របខ័ណ្ឌគោលនយោបាយ និងវិធានការបន្ធូរបន្ថយ ........ 5

២.៤ សំនួរគន្លឹះសម្រាប់កម្រងសំនួរ ........ 7

៣. ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ........ 8

៣.១ ស្ថានភាពទូទៅនៃការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទនៅក្នុងប្រទេសកម្ពុជា ........ 8

៣.២ មូលហេតុនៃការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ........ 13

៣.៣ ការបង្កាទប់ស្កាត់ ការអនុវត្តច្បាប់ និងកិច្ចការពារ ........ 14

៣.៤ សំនួរគន្លឹះសម្រាប់កម្រងសំនួរ ........ 16

៤. សេចក្តីសន្និដ្ឋាន ........ 17

ឯកសារយោង ........ 19

## ១. សេចក្តីផ្តើម

ការធ្វើចំណាកស្រុក ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ នៅតែជាបញ្ហាសង្គមដ៏សំខាន់នៅក្នុងប្រទេសកម្ពុជា។ អស់រយៈពេលជាង១០ឆ្នាំកន្លងទៅនេះ ប្រទេសកម្ពុជាបានទទួលបទពិសោធន៍ពីកំណើនសេដ្ឋកិច្ចលើការធ្វើចំណាកស្រុកក្នុង និងក្រៅប្រទេស ជាពិសេសប្រទេសថៃ កូរ៉េខាងត្បូង និងប្រទេសម៉ាឡេស៊ី។ ការស្រាវជ្រាវនេះត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបនឹងសំណើរបស់តំណាងគណៈកម្មការទី៨ ព្រឹទ្ធសភានៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧ ពាក់ព័ន្ធបញ្ហាការធ្វើចំណាកស្រុក និងការជួញដូរមនុស្ស។ ឯកសារស្រាវជ្រាវនេះនឹងប្រើប្រាស់ជាអត្ថបទសារតាក្នុងការផ្តល់ព័ត៌មាន និងការវិភាគបរិបថពាក់ព័ន្ធបញ្ហាដែលបានរៀបរាប់ខាងលើជូនដល់គណៈប្រតិភូ។ ជាពិសេស ការស្រាវជ្រាវនេះមានគោលបំណងពិនិត្យមើលវិសាលភាព និងមូលហេតុនៃការធ្វើចំណាកស្រុកទៅក្រៅប្រទេស ការទប់ស្កាត់ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ហើយស្វែងរកថាតើគួរធ្វើអ្វីខ្លះដើម្បីកាត់បន្ថយបញ្ហាទាំងអស់នេះ។ ការស្រាវជ្រាវនេះផ្តោតទៅលើសំនួរខាងក្រោម៖

១. តើស្ថានភាព និងមូលហេតុអ្វីខ្លះដែលបណ្តាលឲ្យមានការធ្វើចំណាកស្រុក ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទក្នុងប្រទេសកម្ពុជា?

២. តើគួរធ្វើអ្វីខ្លះដើម្បីដោះស្រាយនូវបញ្ហាប្រឈម ជាពិសេសទាក់ទងនឹងការទប់ស្កាត់ និងការអនុវត្តន៍ច្បាប់?

៣. តើមានកម្រងសំណួរខ្លីៗអ្វីខ្លះត្រូវយកមកពិភាក្សានៅពេលដែលមានការសិក្សាស្តីពីការធ្វើចំណាកស្រុក ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទក្នុងប្រទេសកម្ពុជា?

លទ្ធផលនៃការសិក្សានេះគឺបានមកពីការធ្វើសំយោគឯកសារស្រាវជ្រាវ ឯកសាររបស់រាជរដ្ឋាភិបាល និងការវិភាគទិន្នន័យដែលមានស្រាប់ ឬតាមប្រព័ន្ធអនឡាញ។ ឯកសារស្រាវជ្រាវនេះក៏ភ្ជាប់ជាមួយនូវកម្រងសំនួរគោល២ប្រភេទ ដោយយោងតាមសំណូមពររបស់ម្ចាស់សំណើរក្នុងពេលប្រជុំ។ កម្រងសំនួរទាំងនោះត្រូវបានបង្កើតឡើងសម្រាប់គណៈកម្មការប្រើប្រាស់ក្នុងកិច្ចពិភាក្សាជាមួយអ្នកពាក់ព័ន្ធ ពេលចុះបេសកកម្មរបស់ខ្លួន។

## ២. ស្ថានភាពការធ្វើចំណាកស្រុកនៅក្នុងប្រទេសកម្ពុជា

ការធ្វើចំណាកស្រុក គឺជាបញ្ហាសកលដែលត្រូវបានជំរុញដោយសកលភាវូបនីយកម្ម សង្គមនយោបាយ និងការអភិវឌ្ឍខាងសេដ្ឋកិច្ច។[1] បញ្ហានេះគឺមិនមែនជាបញ្ហាថ្មីសម្រាប់ប្រទេសកម្ពុជាទេ។

មុនទសវត្សឆ្នាំ១៩៩០ ការធ្វើចំណាកស្រុករបស់ប្រជាជនកម្ពុជាគឺជាការគេចចេញពីសង្គ្រាម។ ចាប់តាំងពីបាន សន្តិភាពពេញលេញឡើងវិញ ចំនួនប្រជាជនធ្វើចំណាកស្រុកទៅកាន់ប្រទេសដទៃ ដោយសារតែមូលហេតុសេដ្ឋកិច្ចបានកើនឡើង។

ប្រទេសកម្ពុជាមានប្រជាជន ចំនួន១៤,៩លាននាក់ ដែលមានអត្រាកំណើន១,៣ភាគរយ និងកម្លាំងពលកម្មប្រហែល ៧លាននាក់។[2] ស្ថានភាពប្រជាសាស្ត្រនេះមានន័យថាប្រទេសកម្ពុជាបាននឹងកំពុងព្យាយាមផ្តល់ឱកាសការងារឲ្យបានគ្រប់គ្រាន់សម្រាប់យុវជន និងកំណើនប្រជាជន។មានការប៉ាន់ប្រមាណថាកម្លាំងពលកម្មវ័យក្មេង ចំនួន៣០០.០០០នាក់ បានចូលក្នុងទីផ្សារការងារនៅក្នុងប្រទេសកម្ពុជាជារៀងរាល់ឆ្នាំ ហើយភាគច្រើននៃពួកគេគ្មានជំនាញឡើយ។ វិស័យរោងចក្រកាត់ដេរ ដែលជាផ្នែកមួយដ៏សំខាន់សម្រាប់វិស័យឧស្សាហកម្ម បានប្រើប្រាស់កម្លាំងពលកម្មប្រហែល ២៥០.០០០នាក់។ នេះមានន័យថា ភាគច្រើននៃប្រជាជនកម្ពុជាដែលឋិតក្នុងអាយុធ្វើការកំពុងស្ថិតនៅក្នុងវិស័យដ៏ទៃទៀតជាពិសេសក្នុងវិស័យកសិកម្ម។ រាជរដ្ឋាភិបាលបានប្រឈមនឹងបញ្ហាជាច្រើនក្នុងការផ្តល់ឲ្យយុវជនកម្ពុជានូវជំនាញដែលត្រូវការដើម្បីចូលក្នុងទីផ្សារការងារ។[3] នេះបង្ហាញឲ្យឃើញយ៉ាងច្បាស់ថាការខ្វះខាតជំនាញតាមតម្រូវការក្នុងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានជម្រុញឲ្យប្រជាជនធ្វើចំណាកស្រុកទៅកាន់ប្រទេសដ៏ទៃដើម្បីស្វែងរកការងារធ្វើនៅកន្លែងផ្សេង។[4]

ការធ្វើចំណាកស្រុកនៅក្នុងប្រទេស កើតមានច្រើននៅតាមព្រំដែនកម្ពុជា ថៃ និងវៀតណាម [5]។ ការសិក្សាផ្សេងទៀតបានសង្កត់ធ្ងន់ថាពលករចំណាកស្រុកភាគច្រើនមកពីខេត្តព្រៃវែង ស្វាយរៀង កំពង់ចាម បន្ទាយមានជ័យ និងខេត្តពោធិសាត់។[4] ដោយមានការថយចុះអត្រាកំណើត សេដ្ឋកិច្ចរឹងមាំ និងតម្រូវការកម្លាំងពលកម្ម ប្រទេសថៃគឺជាគោលដៅទាក់ទាញបំផុតសម្រាប់ការធ្វើចំណាកស្រុកឆ្លងដែនសម្រាប់យុវជនកម្ពុជា។[5] យោងតាមស្ថិតិដែលផ្តល់ដោយក្រសួងការងារនៅចុងឆ្នាំ២០១៦ចំនួនសរុបនៃពលករចំណាកស្រុកនៅក្នុងប្រទេសថៃឈានដល់ចំនួន១.០៥៦.៣៥៨នាក់(៣១០.០០០ជនចំណាកស្រុកគ្មានឯកសារ)។ ប្រទេសកូរ៉េខាងត្បូង បានក្លាយជាគោលដៅទីពីរសម្រាប់ការធ្វើចំណាកស្រុករបស់ប្រជាជនកម្ពុជាដោយសារតែប្រាក់ឈ្នួលមានតម្លៃខ្ពស់ជាង។ បច្ចុប្បន្ននេះមានពលករចំនួន៤៤.២៣០នាក់កំពុងធ្វើការនៅក្នុងប្រទេសនេះ។ ចំនួនពលករចំណាកស្រុកកម្ពុជានៅប្រទេសម៉ាឡេស៊ីមាន ចំនួន ១,៧៧៦នាក់ ក្នុងឆ្នាំ២០០៥ ហើយកើនឡើង ចំនួន១០ដង ក្នុងរយៈពេល៥ឆ្នាំ និងនៅឆ្នាំ២០១៦ សមាមាត្រស្ថិតនៅចំនួន៤៦.៥៤១នាក់។ មានការប៉ាន់ប្រមាណថាមានពលករចំណាកស្រុកកម្ពុជា ចំនួន ៣.៨៩៧នាក់ បានធ្វើការនៅក្នុងប្រទេសជប៉ុន និងរាប់រយនាក់នៅក្នុងប្រទេសសឹង្ហបុរី។[6]

ក្នុងទសវត្សរ៍កន្លងមក ភាគច្រើននៃអ្នកទាំងនោះធ្វើចំណាកស្រុកទៅប្រទេសថៃ គឺជាជនចំណាកស្រុក "មិនទៀងទាត់"។ ការធ្វើចំណាកស្រុកមិនទៀងទាត់អាចត្រូវបានកំណត់ថាជា "ចលនាខុសច្បាប់ដើម្បីធ្វើការនៅក្នុងប្រទេសផ្សេងទៀតដោយពុំមានការអនុញ្ញាត"។[4] ការសិក្សាដូចគ្នានេះបានគូសបញ្ជាក់ពីភាពខុសគ្នាយ៉ាងខ្លាំងនៅក្នុងស្ថានភាពសង្គមសេដ្ឋកិច្ចរវាងអ្នកធ្វើចំណាកស្រុកទៀងទាត់ និងមិនទៀងទាត់។ ឧទាហរណ៍ អ្នកធ្វើចំណាកស្រុកមិនទៀងទាត់ច្រើនតែទៅធ្វើការងារដែលគ្មានជំនាញ មានការអប់រំទាប ការចំណាយលើការប្រើប្រាស់ និងទ្រព្យសម្បត្តិ។[4] អ្នកធ្វើចំណាកស្រុកមិនទៀងទាត់ ឬដោយខុសច្បាប់ត្រូវបានគេរកឃើញថាមានភាពងាយរងគ្រោះជាងអ្នកដែលធ្វើចំណាកស្រុកដោយស្របច្បាប់(ផ្នែក៣.២ខាងក្រោម)។

## *២.១ មូលហេតុនៃការធ្វើចំណាកស្រុក*

មូលហេតុនៃការធ្វើចំណាកស្រុកត្រូវបានបូកបញ្ចូលគ្នារវាងកត្តា "ទាក់ទាញ" និងកត្តា "ជំរុញ"។ កត្តាជំរុញត្រូវបានគេយល់ថា វាពាក់ព័ន្ធនឹងលក្ខខ័ណ្ឌដែលជំរុញឲ្យមានការសម្រេចចិត្តធ្វើចំណាកស្រុកទៅប្រទេសផ្សេងដើម្បីស្វែងរកជីវភាពប្រសើរជាងមុន។ ទាំងនេះរួមមានកង្វះឱកាសការងារ សេវាកម្មសង្គមទន់ខ្សោយ វិបត្តិគ្រួសារ ឬ វិបត្តិតំណាលគ្នាដទៃ[1] និងភាពក្រីក្រ។ កត្តាទាក់ទាញ សំដៅទៅលើលក្ខខណ្ឌដែលទាក់ទាញមនុស្សពីកន្លែងផ្សេងមករស់នៅ ក្នុងគោលបំណងលើកកម្ពស់ជីវភាពរស់នៅកាន់តែប្រសើរឡើង។ កត្តាទាំងនោះរួមមានឱកាសការងារ សម្បូរធនធានធម្មជាតិ សេវាកម្មសង្គមល្អ សន្តិភាព និងស្ថេរភាព។[1] នៅក្នុងប្រទេសកម្ពុជា ការរួមផ្សំនៃកត្តាទាំងពីរបានធ្វើឲ្យមានការធ្វើចំណាកស្រុក។

ការគេចចេញពីភាពក្រីក្រដើម្បីស្វែងរកជីវភាពល្អប្រសើរ និងប្រាក់ចំណូលខ្ពស់គឺជាហេតុផលមូលដ្ឋានសម្រាប់ការធ្វើចំណាកស្រុក។ ការសិក្សាជាច្រើនដែលតាមដានលើបញ្ហាការធ្វើចំណាកស្រុកនៅប្រទេសកម្ពុជាបញ្ជាក់ថា កត្តាជំរុញសំខាន់បំផុតសម្រាប់ការធ្វើចំណាកស្រុកក្នុងប្រទេសកម្ពុជាគឺ កង្វះការងារនៅក្នុងសហគមន៍ និងប្រាក់ឈ្នួលទាប។ របកគំហើញនេះទទួលបានពី របាយការណ៍ដែលបានមកពីការធ្វើបទសម្ភាសន៍ជាង៧០%នៃជនចំណាកស្រុកដែលបានត្រឡប់មកវិញ។[7] ប្រាក់ឈ្នួលអប្បបរមាដែលបានរាយការណ៍នៅក្នុងប្រទេសកម្ពុជាមានតម្លៃចន្លោះពី ២,៥ ដុល្លារ ដល់៨ ដុល្លារក្នុងមួយថ្ងៃ។ នៅក្នុងប្រទេសថៃ ប្រាក់ឈ្នួលអប្បបរមាមានតម្លៃប្រមាណជា ៣០០ បាត (ប្រហែល១០ដុល្លារ) ហើយវាជាកត្តាមួយក្នុងចំនោមកត្តាសំខាន់ៗដែលទាក់ទាញការធ្វើចំណាកស្រុក។

---

[1] វិបត្តិតំណាលគ្នាដទៃសំដៅលើវិបត្តិនានាដែលកើតឡើងទៅលើមនុស្សក្នុងពេលតែមួយ។

ការសិក្សាជាច្រើនបានរកឃើញថា ការជាប់បំណុលក៏ជាមូលហេតុមួយជម្រុញឲ្យប្រជាជនធ្វើចំណាកស្រុកដែរ។[5, 7] ភាពកង្វះជំនាញដែលធ្វើឲ្យមនុស្សពិបាកក្នុងការរកការងារធ្វើនៅក្នុងប្រទេសបានជំរុញឲ្យពួកគេធ្វើចំណាកស្រុកដើម្បីធ្វើការងារជាបណ្តោះអាសន្ន ឬយូរអង្វែងនៅប្រទេសថៃ។[7] កង្វះដីដែលអំណោយផលក៏ជាកត្តាជំរុញដ៏សំខាន់មួយដែលជំរុញឲ្យប្រជាជនចាកចេញពីសហគមន៍របស់ពួកគេ និងចំណាកស្រុកទៅធ្វើការនៅកន្លែងផ្សេងទៀត។[8] ស្ថានភាពនេះឆ្លុះបញ្ចាំងពីការកើនឡើងនៃចំនួនអ្នកគ្មានដីធ្លីក្នុងចំណោមអ្នកក្រីក្រនៅជនបទ។[9] ការសិក្សាផ្សេងទៀតបង្ហាញពីមូលហេតុដែលពាក់ព័ន្ធ ការខូចខាតផលដំណាំ ដែលជំរុញឲ្យប្រជាជនផ្លាស់ទីលំនៅចេញពីសហគមន៍។

ជនចំណាកស្រុកខ្លះបានជ្រើសរើសយកការធ្វើចំណាកស្រុកដោយខុសច្បាប់ ឬដោយគ្មានឯកសារ ជាពិសេសទៅប្រទេសជិតខាងដូចជាប្រទេសថៃ ដោយសារតែការចំណាយខ្ពស់ និងការដាក់ពាក្យសុំឯកសារ (ជាពិសេសលិខិតឆ្លងដែន)មានរយៈពេលយូរ។[8] ការធ្វើចំណាកស្រុកទៅប្រទេសថៃស្របច្បាប់មានតម្លៃប្រហែល ៧៤៧ដុល្លារ ដែលមានអត្រាខ្ពស់ជាង៥ដងបើប្រៀបធៀបទៅនឹងការធ្វើចំណាកស្រុកដោយខុសច្បាប់ហើយក្នុងករណីភាគច្រើនអ្នកធ្វើចំណាកស្រុកត្រូវខ្ចីបុលដើម្បីចំណាយ។[10] កម្រិតអប់រំមិនមានជាប់ទាក់ទងទៅនឹងការសម្រេចចិត្តជ្រើសរើសការធ្វើចំណាកស្រុកដែលមានសុវត្ថិភាពនោះទេ។[7]

## *២.២ ផលប៉ះពាល់នៃការធ្វើចំណាកស្រុក*

ផលប៉ះពាល់នៃការធ្វើចំណាកស្រុកគឺមានទាំងវិជ្ជមាន និងអវិជ្ជមាន អាស្រ័យលើការធ្វើចំណាកស្រុកជាពិសេសប្រភេទការងារដែលពលករធ្វើការ ទីតាំង និងស្ថានភាពផ្លូវច្បាប់របស់ពលករចំណាកស្រុកខ្លួនឯង។[1, 4, 5] លទ្ធផលផ្សេងគ្នាបានមកពីការជ្រើសរើសប្រភេទក្រុមហ៊ុនពលករដើម្បីនាំពួកគេទៅរកការងារធ្វើ[5]។ ការធ្វើចំណាកស្រុកជាមួយក្រុមហ៊ុនពលករដែលមានអាជ្ញាប័ណ្ណទំនងជានឹងផ្តល់ប្រាក់ចំណូលខ្ពស់សម្រាប់ពលករនៅក្នុងប្រទេសថៃ។ [7]

ខាងផ្នែកវិជ្ជមាន ការធ្វើចំណាកស្រុកបានធ្វើឲ្យប្រសើរឡើងដល់សុខុមាលភាពនៅក្នុងគ្រួសារ។ ប្រភពខុសៗគ្នាបានបង្ហាញពីទំហំនៃការផ្ញើរប្រាក់ខុសៗគ្នាដែលបញ្ជូនមកប្រទេសកម្ពុជាដោយពលករ ចំណាកស្រុកទៅក្រៅប្រទេស។ ការផ្ញើប្រាក់ពីពលករចំណាកស្រុកកើនឡើងយ៉ាងខ្លាំង។ វាមានប្រហែល ២០០លាន ឬ ៣.២៣ ភាគរយនៃផលិតផលសរុបក្នុងស្រុក(GDP) នៅក្នុងឆ្នាំ២០០៥។ ស្ថិតិចុងក្រោយបំផុតដោយក្រសួងការងារបង្ហាញថាការផ្ញើប្រាក់ពីពលករចំណាកស្រុកបានឈានដល់ប្រមាណជា ១,៧ ពាន់លានដុល្លារក្នុងឆ្នាំ ២០១៦ ហើយវាអាចមានចំនួនខ្ពស់ជាងនេះ ដោយសារសមាមាត្រពលករមួយចំនួនមិនត្រូវបានកត់ត្រា។[6] ទំហំមាត្រដ្ឋានដ៏ធំសម្បើមនៃការធ្វើចំណាកស្រុកពន្យល់ពីការរកឃើញ

ដែលបានអះអាងពីទំនាក់ទំនងរវាងការធ្វើចំណាកស្រុក ការកាត់បន្ថយភាពក្រីក្រ និងការធ្វើឲ្យប្រសើរឡើងដល់សុខុមាលភាពគ្រួសាររបស់ពលករចំណាកស្រុក។[4, 5, 10, 11, 12] ការធ្វើចំណាកស្រុកក៏មានទំនាក់ទំនងវិជ្ជមានជាមួយនឹងការសម្រេចបាននូវការអប់រំផងដែរ ថ្វីបើអត្រាបោះបង់ចោលការសិក្សាគឺមានកម្រិតខ្ពស់ជាងបើធៀបនឹងអ្នកដែលមិនមែនជាគ្រួសាររបស់ជនចំណាកស្រុក។ នេះមានន័យថាប្រាក់ចំណូលពីការធ្វើចំណាកស្រុកទំនងជារួមចំណែកដល់ការគាំទ្រដល់ការអប់រំកុមារ។[13]

ខាងផ្នែកអវិជ្ជមាននៃការធ្វើចំណាកស្រុក អាចត្រូវបានគេមើលឃើញថាមានភាពងាយរងគ្រោះការរំលោភបំពាន និងរស់នៅក្នុងស្ថានភាពយ៉ាប់យ៉ឺន។ ការសិក្សាជាច្រើនបានបញ្ជាក់ថាពលករចំណាកស្រុកភាគច្រើនចូលរួមនឹងការងារ៣ប្រភេទ (ការងារកង្វក់ គ្រោះថ្នាក់ និងលំបាក)[3Ds: Dirty, Dangerous and Dislike]។[4, 7, 14] ការស្ទង់មតិជាមួយនឹងជនចំណាកស្រុក ដែលត្រលប់មកវិញពីប្រទេសថៃបានបង្ហាញថា ប្រហែល២០ភាគរយនៃពួកគេត្រូវបានរាយការណ៍ថាត្រូវគេរំលោភបំពាន។[7] ពលករចំណាកស្រុកជាពិសេសក្នុងវិស័យនេសាទ ត្រូវបានគេរាយការណ៍ថាបានរស់នៅក្នុងស្ថានភាពយ៉ាប់យ៉ឺន ទីកន្លែងតូចចង្អៀតហើយគ្មានអនាម័យ និងត្រូវបានប្រឈមមុខនឹងអំពើហឹង្សា និងការប្រើប្រាស់គ្រឿងញៀន។[7] ពលករដែលគ្មានឯកសារ ពុំសូវទទួលបានសេវាសុខភាព ហើយពួកគេព្យាយាមរត់គេចពីការចាប់ខ្លួន និងនិរទេស។ លើសពីនេះទៀត ពួកគេប្រឈមនឹងបញ្ហាធំជាងអ្នកធ្វើចំណាកស្រុកដែលមានឯកសារគ្រប់គ្រាន់។ ពួកគេទំនងជាត្រូវបានគេនិរទេស ត្រឡប់ទៅប្រទេសវិញ។ ឧទាហរណ៍ក្នុងឆ្នាំ២០១៤ ជនចំណាកស្រុកចំនួនប្រហែល៦៩៣.៦៣០នាក់ រួមទាំងអ្នកនៅក្នុងបន្ទុក ចំនួន ៤២.៣៩៥នាក់ បានចាកចេញពីប្រទេសថៃបន្ទាប់ពីមានការផ្លាស់ប្តូរ សភាពការណ៍នយោបាយនៅក្នុងប្រទេសថៃដោយខ្លាចមានការចាប់ខ្លួន។[2] ដោយអវត្តមានឪពុក ម្តាយ របស់ពួកគេ កុមារនៃគ្រួសារដែលបានធ្វើចំណាកស្រុកកំពុងប្រឈមនឹងគ្រោះថ្នាក់ខ្ពស់ ជំងឺផ្សេងៗ និងទំនងជាខ្វះអាហាររូបត្ថម្ភ។[13] ផលវិបាកមួយទៀតនៃការធ្វើចំណាកស្រុកគឺការបាត់បង់កំលាំងពលកម្ម រារាំងការធ្វើកសិកម្ម ឬសកម្មភាពសេដ្ឋកិច្ចដទៃទៀតនៅក្នុងសហគមន៍កំណើតរបស់គេ។

## *២.៣ ក្របខ័ណ្ឌគោលនយោបាយ និងវិធានការបន្ធូរបន្ថយ*

គោលនយោបាយស្តីពីការធ្វើចំណាកស្រុក បានប្រែប្រួលជាបន្តបន្ទាប់ទៅតាមពេលវេលា។ គោលបំណងទូទៅគឺដើម្បីគ្រប់គ្រង ការពារ និងផ្តល់អំណាចដល់ពលករចំណាកស្រុកកម្ពុជា។ គោលនយោបាយទី១ត្រូវបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រនៃក្រសួងការងារក្នុងឆ្នាំ ២០០៩-២០១២។ គោលនយោបាយនេះផ្តោតលើបញ្ហាបី៖(១) កែលម្អសេវាគ្រប់គ្រងសម្រាប់ពលករចំណាកស្រុកកម្ពុជានៅក្រៅប្រទេសតាមរយៈក្រុមហ៊ុនឯកជន (២)បង្កើតប្រព័ន្ធអនុញ្ញាតិការងារនៅក្នុងប្រទេសកម្ពុជា និង

(៣)ផ្តល់វិធានការការពារពលករចំណាកស្រុក។[4] បន្ទាប់ទៀត គោលនយោបាយដែលមានស្រាប់ត្រូវបានធ្វើបច្ចុប្បន្នភាពទៅក្នុង «គោលនយោបាយធ្វើចំណាកស្រុកដើម្បីការងារ ឆ្នាំ ២០១៥ -២០១៨ (Labour Migration Policy 2015-2018)» ដែលជាគោលនយោបាយទី១ ដែលផ្តោតការយកចិត្តទុកដាក់សំខាន់ទៅលើការដោះស្រាយបញ្ហាការធ្វើចំណាកស្រុករបស់ពលករកម្ពុជា។ គោលនយោបាយនេះបានកំណត់លើគោលដៅដើម្បីគ្រប់គ្រង និង ការពារពលករចំណាកស្រុកប្រកបដោយប្រសិទ្ធភាព និងដើម្បីបង្កើនផលប៉ះពាល់ពីការធ្វើចំណាកស្រុក។ គោលនយោបាយនេះត្រូវបានរៀបចំឡើងតាមរបៀបដែលមានជាប់ទាក់ទងជាមួយផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ(National Strategic Development Plan: NSDP) ដោយវិភាគពីគំរូចរន្តនៃការធ្វើចំណាកស្រុកការងារនៅក្នុងប្រទេសកម្ពុជា ការផ្លាស់ប្តូរប្រជាសាស្រ្តក៏ដូចជាការអភិវឌ្ឍន៍ថ្នាក់ជាតិ និងថ្នាក់តំបន់។[3]

ក្រៅពីក្របខ័ណ្ឌគោលនយោបាយ សិទ្ធិរបស់ពលករចំណាកស្រុកក៏ត្រូវបានការពារដោយច្បាប់អន្តរជាតិ និងច្បាប់ជាតិ រួមទាំងអនុក្រឹត្យផ្សេងៗ ប្រកាស អនុស្សរណៈយោគយល់គ្នា(MoUs)ជាមួយប្រទេសដែលជាម្ចាស់ផ្ទះ រួមមានប្រទេសថៃ ម៉ាឡេស៊ី និងកូរ៉េខាងត្បូង ព្រមទាំងអនុសញ្ញាអន្តរជាតិនានា។ ច្បាប់ទាំងនេះត្រូវបានដាក់ឲ្យអនុវត្តដើម្បីលើកកម្ពស់ និងការពារពលករចំណាកស្រុក។ មិនមានការសិក្សាទូលំទូលាយដើម្បីបង្ហាញអំពីមូលហេតុដែលយន្តការច្បាប់ទាំងនេះត្រូវបានអនុវត្តនិងពង្រឹងនោះទេ។

ដើម្បីដោះស្រាយបញ្ហាការធ្វើចំណាកស្រុក និងដើម្បីលើកកម្ពស់លទ្ធផលវិជ្ជមានទាមទារឲ្យមានការយល់ដឹងដ៏ស្មុគស្មាញអំពីបញ្ហានេះ ការសម្របសម្រួលល្អរវាងភាគីពាក់ព័ន្ធ និងស្ថាប័នក៏ដូចជាក្របខ័ណ្ឌគោលនយោបាយល្អ។ មានជម្រើសមួយចំនួនដែលត្រូវបានលើកឡើងដោយការសិក្សាផ្នែកការធ្វើចំណាកស្រុកនៅក្នុងប្រទេសកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ ការសង្ខេបនេះបានបង្ហាញពីចំណុចសំខាន់មួយចំនួនៈ

- រាល់វិធានការទាំងឡាយ ដែលជួយកាត់បន្ថយការចំណាយទៅលើការរៀបចំឯកសារសម្រាប់ជនចំណាកស្រុកក្រីក្រនឹងមានឥទ្ធិពលវិជ្ជមានទៅលើពួកគេ នឹងជួយលើកកម្ពស់ការធ្វើចំណាកស្រុកស្របច្បាប់ ហើយវាអាចជួយផ្តល់ឱកាសដល់ពួកគេក្នុងការទទួលបានលក្ខខណ្ឌការងារល្អ និងប្រាក់ខែច្រើន ហើយសំខាន់បំផុតគឺការទទួលបានកិច្ចការពារផ្នែកច្បាប់ និងសេវាកម្មសង្គម[8]
- កិច្ចខិតខំប្រឹងប្រែងគួរត្រូវបានធ្វើឡើងដើម្បីផ្សព្វផ្សាយព័ត៌មានស្តីពី ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព តាមរយៈការធ្វើយុទ្ធនាការអប់រំដល់សហគមន៍។ ហើយនោះក៏រួមចំណែកដល់ការបង្កើនការយល់ដឹងពីហានិភ័យនៃការធ្វើចំណាកស្រុកខុសច្បាប់ និងដើម្បីបង្កើនកិច្ចការពារ។ នេះ

អាចត្រូវបានធ្វើតាមរយៈថ្នាក់ក្រោមជាតិ ជាពិសេសក្រុមប្រឹក្សាឃុំ សង្កាត់ និង មជ្ឈមណ្ឌលធនធានថ្នាក់ខេត្ត[7]

- ភាពក្រីក្រពុំរ៉ែ កង្វះនៃឱកាសការងារ កង្វះនៃជំនាញគឺជាមូលដ្ឋានគ្រឹះនៃការធ្វើចំណាកស្រុក។ នេះបង្ហាញពីទំនាក់ទំនងដ៏រឹងមាំរវាងការអភិវឌ្ឍន៍នៅក្នុងសហគមន៍នៃប្រភពដើម និងការធ្វើចំណាកស្រុក។ ថ្វីបើវានៅតែជាសម្មតិកម្មក៏ពិតមែន ក៏ប៉ុន្តែវាទំនងជាបង្ហាញថា ការជំរុញអោយមានការអភិវឌ្ឍន៍នៅក្នុងសហគមន៍ បង្កើនផលិតភាពកសិកម្ម និងទីផ្សារ បង្កើតការងារ បង្កើនលទ្ធភាពទទួលបានសេវាសង្គម ការផ្តល់ជំនាញនឹងជួយកាត់បន្ថយការធ្វើចំណាកស្រុក និងកាត់បន្ថយហានិភ័យនៃការធ្វើចំណាកស្រុក។[4]

## *២.៤ សំនួរគន្លឹះសម្រាប់កម្រងសំនួរ*

សំណួរដាក់ស្តែងដើម្បីតាមដានពីវឌ្ឍនភាពនៃការធ្វើចំណាកស្រុកមានដូចខាងក្រោម៖

- តើការងារប្រភេទណាខ្លះដែលពលករចំណាកស្រុកចូលរួម? ហើយតើពលករចំណាកស្រុកស្វែងរកការងារនេះយ៉ាងដូចម្តេច? ហេតុអ្វីពលករចំណាកស្រុកធ្វើការជ្រើសរើសការងារនេះ? សូមពណ៌នាអំពីស្ថានភាពនៃការងារ។
- តើអ្នកណាខ្លះធ្វើចំណាកស្រុកក្នុងសហគមន៍នេះ? ហេតុអ្វី?
- តើពលករធ្វើចំណាកស្រុកទៅកាន់តំបន់គោលដៅសំខាន់អ្វីខ្លះ? ហេតុអ្វី?
- តើសមាមាត្រនៃប្រជាជនធ្វើចំណាកស្រុកពីសហគមន៍នេះមានចំនួនប៉ុន្មាន?
- តើក្នុងលក្ខខណ្ឌអ្វីខ្លះដែលពលករធ្វើការជ្រើសរើសដើម្បីធ្វើចំណាកស្រុក(មានឯកសារ ឬគ្មានឯកសារ)? ហើយអ្វីដែលជាមូលហេតុនៃជម្រើសនេះ?
- តើពលករចំណាកស្រុកបានទទួលប្រាក់ឈ្នួលក្នុងមួយថ្ងៃ ឬមួយខែពីការងាររបស់ពួកគេក្នុងតម្លៃប៉ុន្មាន? តើពួកគេអាចផ្ញើប្រាក់មកផ្ទះបានប៉ុន្មាន?
- តើផលប៉ះពាល់វិជ្ជមានពីការធ្វើចំណាកស្រុកទៅលើជីវភាពរស់នៅរបស់គ្រួសារពលករមានអ្វីខ្លះ? (ឧ. ចំណូលកើនឡើង ទ្រព្យសម្បត្តិកាន់តែច្រើន ការទទួលទានកាន់តែច្រើន លំនៅដ្ឋានដែលល្អប្រសើរ សមត្ថភាពទប់ទល់នឹងហានិភ័យខ្ពស់ ការធ្វើពិពិធកម្មជីវភាព (livelihood diversification)និងផ្សេងៗ ...)? ដោយរបៀបណា ហើយហេតុអ្វី?
- តើការធ្វើចំណាកស្រុកមានផលប៉ះពាល់ដល់សហគមន៍យ៉ាងដូចម្តេច? (កង្វះពលកម្មសម្រាប់ការធ្វើកសិកម្មជាដើម)

- តើផលប៉ះពាល់អវិជ្ជមាននៃការធ្វើចំណាកស្រុកទៅលើជីវភាពបុគ្គល និងគ្រួសារ (ការរំលោភបំពាននិងការធ្វើអាជីវកម្ម ការបង្កើនហានិភ័យសុខភាព គ្រោះថ្នាក់ និងការចាកចេញចោលពីកូន)មានអ្វីខ្លះ? ហេតុអ្វីបានជាវាកើតឡើង? តើអ្នកអាចទប់ទល់នឹងហានិភ័យ និងឧប្បត្តិហេតុបែបនេះបានដោយរបៀបណា?
- តើកត្តាអ្វីខ្លះដែលរារាំងមនុស្សពីការជ្រើសរើសការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព?
- តើអ្វីជាបញ្ហាប្រឈមដែលពួកគេជួបក្នុងអំឡុងពេលធ្វើចំណាកស្រុក ក្នុងអំឡុងពេលស្នាក់នៅ និងត្រឡប់មកវិញ?
- តើមានជំនួយអ្វីខ្លះដែលត្រូវបានផ្តល់ជូនដល់ពលករចំណាកស្រុកដោយអាជ្ញាធរ និងអង្គការក្រៅរដ្ឋាភិបាល?
- តើពលករយល់យ៉ាងដូចម្តេចអំពីប្រសិទ្ធភាព និងផលប៉ះពាល់នៃយន្តការច្បាប់ និងគោលនយោបាយដែលជាជំនួយទាំងអស់នោះ? ហើយអ្វីខ្លះដែលជាបញ្ហាខ្វះខាតក្នុងការផ្តល់ជំនួយទាំងនោះ?
- តើគួរធ្វើយ៉ាងណាដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានពីការធ្វើចំណាកស្រុក? សូមជ្រើសរើសអាទិភាពចំនួនបី?

## ៣. ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ

### *៣.១ ស្ថានភាពទូទៅនៃការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទនៅក្នុងប្រទេសកម្ពុជា*

ប្រទេសកម្ពុជានៅតែជាប្រភព កន្លែងឆ្លងកាត់ ហើយនឹងជាគោលដៅសម្រាប់ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ។ ទោះបីជាកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការលុបបំបាត់ការជួញដូរមនុស្សដើម្បីរុញច្រានប្រទេសឲ្យចេញពីបញ្ជីតាមដានលំដាប់ថ្នាក់លេខ២(ឃ្លាំមើល) នៅឆ្នាំ ២០១៦ក៏ដោយ ក៏កម្ពុជានៅតែអន់ជាងប្រទេសដទៃទៀត។[15] ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទត្រូវបានគេចាត់ទុកថាជាបទល្មើសផ្នែកព្រហ្មទណ្ឌ និងជាប្រភេទទាសភាពសម័យទំនើប[ii] ដោយសារវាពាក់ព័ន្ធនឹងការប្រើប្រាស់កម្លាំង គំរាមកំហែង អំពើហឹង្សា ការបង្ខិតបង្ខំ និងការរំលោភបំពានអំណាចប្រឆាំងនឹងមនុស្សជាតិ។[16] មិនមានទិន្នន័យជាក់លាក់ណាមួយបង្ហាញពីចំនួនប្រជាជនកម្ពុជាបច្ចុប្បន្នដែលកំពុងស្ថិតក្រោមការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទទេ ដោយសារទិន្ន័យទាំងនោះពាក់ព័ន្ធនឹង

[ii] យោងតាមសន្ទស្សន៍ទាសភាពក្នុងឆ្នាំ២០១៦ ទាសភាពសម័យទំនើបសំដៅលើ« ស្ថានភាពនៃការរំលោភបំពាន ដែលមនុស្សមិនអាចបដិសេធ ឬចាកចេញ ដោយសារតែពួកគេទទួលរងការគំរាមកំហែង អំពើហឹង្សា ការបង្ខិតបង្ខំ ការរំលោភបំពានដោយអំណាច ឬបោកបញ្ឆោតចាត់ទុកដូចជាសត្វធាតុ»។

ទិន្នន័យពលរដ្ឋដែលទទួលរងពលកម្មដោយបង្ខំ និងទិន្នន័យការធ្វើចំណាកស្រុក។ ទោះជាយ៉ាងណាក៏ដោយ ទិន្នន័យស្ទង់មតិមូលនិធិដោះលេងឲ្យមានសេរីភាព(Walk Free Foundation)នៅឆ្នាំ ២០១៥ បង្ហាញថាប្រទេសកម្ពុជាមានជនរងគ្រោះប្រមាណ ២៥៦.៨០០នាក់ ស្ថិតក្រោមទាសភាពសម័យទំនើប រួមទាំងការជួញដូរមនុស្ស ដែលក្នុងនោះការបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ មានចំនួន ៥៥.៨០០ នាក់ និងពលកម្មដោយបង្ខំគឺ ២០១.០០០នាក់។[17] វាត្រូវបានគេប៉ាន់ប្រមាណថាទាសភាពសម័យទំនើបនៅកម្ពុជាមានចំនួន ១,៦៤៨% នៃចំនួនប្រជាជនសរុបនៅឆ្នាំ ២០១៥ ដែលចំនួននេះបានធ្វើឲ្យប្រទេសកម្ពុជាក្លាយជាប្រទេសមួយមានអត្រាខ្ពស់បំផុតនៅអាស៊ីអាគ្នេយ៍ និងជាប្រទេសលំដាប់លេខ៣នៅលើពិភពលោក បន្ទាប់ពីប្រទេសកូរ៉េខាងជើង(North Korea) និងអ៊ូសបេគីស្ថាន(Uzbekistan)(សូមមើលតារាងទី ១ និង ២)។[16] ទិន្នន័យស្ទង់មតិមូលនិធិដោះលេងឲ្យមានសេរីភាព(Walk Free Foundation)ក៏បានកំណត់និយមន័យនៃការជួញដូរមនុស្សគឺជាការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងជ្រកកោណ ឬការទទួលយកមនុស្ស (Harbouring or receipt of persons) តាមរយៈការគំរាមកំហែងឬការប្រើប្រាស់កម្លាំង ឬទម្រង់ផ្សេងទៀតនៃការបង្ខិតបង្ខំ ការចាប់ពង្រត់ ការលួចបន្លំ ការបោកបញ្ឆោត ការរំលោភបំពានអំណាចឬ ស្ថានភាពងាយរងគ្រោះសម្រាប់គោលបំណងនៃការជួញដូរ។

**តារាងទី១៖ ការប្រៀបធៀបភាគរយ និងចំនួនជាក់ស្តែងរបស់ប្រជាជនដែលស្ថិតនៅក្រោមទាសភាពសម័យទំនើបនៅប្រទេសកម្ពុជា កូរ៉េខាងជើង និងអ៊ូសបេគីស្ថាន**

| | **កូរ៉េខាងជើង** | **អ៊ូសបេគីស្ថាន** | **កម្ពុជា** |
|---|---|---|---|
| ភាគរយ | ៤,៣៧៣ | ៣,៩៣៧ | ១,៦៤៨ |
| ចំនួនជាក់ស្តែង | ១.១០០.០០០ | ១.២៣៦.៦០០ | ២៥៦.៨០០ |

ប្រភព: សន្ទស្សន៍ទាសភាពសកល ២០១៦[16]

**តារាងទី ២៖ ការប្រៀបធៀបភាគរយ និងចំនួនជាក់ស្តែងរបស់ប្រជាជនដែលស្ថិតក្រោមទាសភាពសម័យទំនើបនៅប្រទេសកម្ពុជា និងអាស៊ីអាគ្នេយ៍**

| ប្រទេស | ចំនួនជាក់ស្តែង | ភាគរយ |
|---|---:|---:|
| កម្ពុជា | ២៥៦.៨០០ | ១,៦៤៨ |
| ថៃ | ៤២៥.៥០០ | ០,៦២៦ |

| | | |
|---|---|---|
| ឡាវ | ២០.០០០ | ០,២៩៥ |
| វៀតណាម | ១៣៩.៣០០ | ០,១៥២ |
| ឥណ្ឌូនេស៊ី | ៧៣៦.១០០ | ០,២៨៦ |
| មីយ៉ាន់ម៉ា | ៥១៥.១០០ | ០,៩៥៦ |
| ម៉ាឡេស៊ី | ១២៨.៨០០ | ០,៤២៥ |
| ប្រ៊ុយណេ | ៣.៤០០ | ០,៨០៥ |
| ហ្វីលីពីន | ៤០១.០០០ | ០,៣៩៨ |
| សិង្ហបុរី | ៩.២០០ | ០,១៦៥ |

ប្រភព: សន្ទស្សន៍ទាសភាពសកល ២០១៦[16]

ទិន្នន័យស្ទង់មតិមូលនិធិដោះលេងឲ្យមានសេរីភាពឆ្នាំ២០១៥ បានលើកឡើងពីវិស័យសំខាន់ៗ ដែលជំរុញឲ្យមានទាសភាពសម័យទំនើប និងការជួញដូរមនុស្សនៅកម្ពុជាគឺ ផលិតកម្ម ការដាំដុះ ការសាងសង់ និងការងារតាមផ្ទះ។[17] ទោះយ៉ាងណាក៏ដោយ ការវិភាគនៃបេសកកម្មយុត្តិធម៌អន្តរជាតិ (International Justice Mission: IJM)ក្នុងឆ្នាំ ២០១៦ ទំនងជាបង្ហាញថាការនេសាទ និងការងារតាមផ្ទះគឺជាវិស័យដែលនាំឲ្យមានការជួញដូរមនុស្សទៅបរទេស។[18] ប៉ុន្តែទិន្នន័យរបស់គណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស (National Committee for Counter Trafficking: NCCT) នៅឆ្នាំ ២០១៦ បានអះអាងបន្ថែមលើការវិភាគរបស់ IJM ថាការរៀបការដោយបង្ខំ គឺជាវិស័យមួយផ្សេងទៀតដែរ។[19]

នៅឆ្នាំ ២០១៦ ទិន្នន័យ NCCT បានបង្ហាញថាប្រទេសកម្ពុជាមានជនរងគ្រោះពីការជួញដូរមនុស្ស ចំនួន ២៩៨នាក់ ដែលត្រូវបានគេធ្វើមាតុភូមិនិវត្តន៍មកកាន់ប្រទេសវិញ ដែលភាគច្រើនមកពីប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី ថៃ និងចិន។[19] ទិន្នន័យនេះហាក់ដូចជាបានចាត់ទុកប្រទេសទាំងនោះទៅជាកន្លែងដែលមានហានិភ័យខ្ពស់សម្រាប់ការជួញដូរមនុស្ស ដែលត្រូវតែប្រុងប្រយ័ត្នសម្រាប់ការធ្វើចំណាកស្រុកនៅក្នុងតំបន់ (សូមមើលតារាងទី 3) ។ ទិន្នន័យរបស់ NCCT នៅឆ្នាំ ២០១៦ បានបង្ហាញថាភាគច្រើននៃជនរងគ្រោះគឺជាពលករចំណាកស្រុកខុសច្បាប់ដែលប្រើប្រាស់បណ្តាញមិនទៀងទាត់ ឬក្រុមហ៊ុនដែលគ្មានអាជ្ញាប័ណ្ណ តាមរយៈសមាជិកសហគមន៍ សាច់ញាតិ ឬបណ្តាញខាងក្រៅសម្រាប់ការធ្វើចំណាកស្រុក។ ជនរងគ្រោះមួយចំនួនត្រូវបានគេរាយការណ៍ផងដែរថាត្រូវបានគេដាក់ឲ្យធ្វើការងារ

ដោយបង្ខំ និងការជួញដូរ បើទោះបីជាពួកគេបានប្រើប្រាស់ភ្នាក់ងារជ្រើសរើសដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវក៏ដោយ។ [15, 19]

**តារាងទី៣៖ ចំនួនជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍ ដែលបានដោះលែងពីប្រទេសគោលដៅ ក្នុងឆ្នាំ ២០១៦**

| ប្រទេសគោលដៅ | សរុប | នាវានេសាទ | ការងារតាមផ្ទះ | រៀបការ | ពលកម្មទូទៅ | របួស និងស្លាប់ |
|---|---|---|---|---|---|---|
| ម៉ាឡេស៊ី | ១០០ | | ៦៣ | | ៣៧ | |
| ឥណ្ឌូនេស៊ី | ៧១ | ៧១ | | | | |
| ចិន | ៦៣ | | | ៤២ | ២១ | |
| ថៃឡង់ | ៤៣ | ១៣ | | | ៣០ | ១៨ |
| វៀតណាម | ១៥ | ៦ | | ៩ | | |
| សូម៉ាលី | ៤ | ៤ | | | | |
| តៃវ៉ាន់ | ១ | | ១ | | | |
| អារ៉ាប៊ីសាអូឌីត | ១ | ១ | | | | |
| **សរុប** | **២៩៨** | **៩៥** | **៦៤** | **៥១** | **៨៨** | **១៨** |

ប្រភព: គណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្សឆ្នាំ 2016។ [19]

គ្រប់ខេត្តនៅប្រទេសកម្ពុជា គឺជាប្រភពនៃការជួញដូរមនុស្ស នេះបើតាមរបកគំហើញពីការសិក្សាពីមុនៗ។ ការជួញដូរមនុស្សកើតឡើងនៅក្នុង និងក្រៅប្រទេសកម្ពុជា។ ការជួញដូរក្នុងប្រទេសកម្ពុជាជារឿយៗពាក់ព័ន្ធនឹងការធ្វើអាជីវកម្មផ្លូវភេទ ដែលក្នុងនោះស្ត្រីវ័យក្មេងត្រូវបានបញ្ជូនទៅធ្វើការនៅផ្ទះបន បន្ទប់ម៉ាស្សា ឬ បារខារ៉ាអូខេ នៅតាមទីក្រុងមួយចំនួនដូចជាក្រុងភ្នំពេញ ក្រុងព្រះសីហនុ ក្រុងប៉ោយប៉ែត កោះកុង ឬសៀមរាប។[20] ការធ្វើអាជីវកម្មផ្លូវភេទលើកុមាររស់តាមចិញ្ចើមផ្លូវជាពិសេសដោយអ្នកទេសចរក៏ត្រូវបានរាយការណ៍ផងដែរ។ ទិន្នន័យរបស់ NCCT នៅឆ្នាំ ២០១៦បានបង្ហាញថាមានក្រុមហ៊ុនអាជីវកម្មគោលដៅចំនួន ៥២៤ ដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជាដែលក្នុងនោះមានក្រុមហ៊ុនអាជីវកម្មចំនួន៧១កន្លែង ត្រូវបានផ្តន្ទាទោសពីបទជួញដូរមនុស្ស និងផ្លូវភេទ។ [19]

ម្យ៉ាងវិញទៀត ការជួញដូរមនុស្សនៅក្រៅប្រទេសកម្ពុជាតែងតែកើតឡើងនៅក្នុងទម្រង់នៃ i)ការជួញដូរមនុស្សតាមរយៈអាពាហ៍ពិពាហ៍ ii) ពលកម្មដោយបង្ខំលើនាវានេសាទ និងការងារតាមផ្ទះ និង iii) ការបង្ខំឲ្យសុំទាន។

**ការជួញដូរតាមរយៈរៀបអាពាហ៍ពិពាហ៍៖** ការជួញដូរសម្រាប់អាពាហ៍ពិពាហ៍បានកើតឡើងក្នុងចំណោម ស្ត្រីខ្មែរមួយចំនួនដែលបានរៀបអាពាហ៍ពិពាហ៍តាមរយៈឈ្មួញកណ្តាលជាមួយបុរសជនជាតិចិន កូរ៉េ និងតៃវ៉ាន់។ ស្ត្រីទាំងនេះស្វែងរកជីវិតដ៏ល្អប្រសើរមួយតាមរយៈការរៀបអាពាហ៍ពិពាហ៍ជាមួយបុរសបរទេស ប៉ុន្តែចុងក្រោយពួកគេបានក្លាយទៅជាមនុស្សដែលត្រូវបានរំលោភបំពានដោយស្វាមី ឬសាច់ញាតិរបស់ស្វាមីពួកគេ និងនៅក្នុងលក្ខខណ្ឌអាក្រក់បំផុត ពួកគេត្រូវបានគេបង្ខំឲ្យធ្វើជាស្រីពេស្យា។ ស្ត្រីខ្លះត្រូវបានគេសន្យាថានឹងទទួលបានការងារនៅរោងចក្រប៉ុន្តែពួកគេត្រូវបានគេបោកបញ្ឆោត និងបង្ខំឲ្យរៀបការដែលប្រឆាំងនឹងឆន្ទៈរបស់ពួកគេ។[16] នៅឆ្នាំ ២០១៦ អាជ្ញាធរចិនបានរាយការណ៍ថាស្ត្រីកម្ពុជាប្រហែល៧.០០០ នាក់បានរៀបអាពាហ៍ពិពាហ៍ជាមួយបុរសជនជាតិចិន ប៉ុន្តែមានតែ ១០០នាក់ប៉ុណ្ណោះដែលត្រូវបានគេរាយការណ៍ថាបានរៀបការស្របច្បាប់។[21] របាយការណ៍ NCCT បានបង្ហាញថាមានអាពាហ៍ពិពាហ៍ស្របច្បាប់រវាងប្រជាជនកម្ពុជា និងជនបរទេសចំនួន ១,៥៤១ នាក់ក្នុងឆ្នាំ ២០១៦ ។[19]

**ពលកម្មដោយបង្ខំលើនាវានេសាទ៖** ការងារដោយបង្ខំកាន់តែធ្ងន់ធ្ងរទៅៗ ក្នុងចំណោមពលករចំណាកស្រុកដែលធ្វើការនៅក្នុងឧស្សាហកម្មនេសាទនៅក្នុងប្រទេសដូចជា ប្រទេសថៃ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី សូម៉ាលី វៀតណាម និងតៃវ៉ាន់។ ករណីពលករចំណាកស្រុកទាំងនេះត្រូវបានគេបង្ខំឲ្យធ្វើការចាប់ពី ១៦ ទៅ ១៨ម៉ោងក្នុងមួយថ្ងៃលើនាវានេសាទដោយគ្មានមធ្យោបាយដើម្បីគេចខ្លួន។[22] ករណីសិក្សាមួយក្នុងប្រទេសឥណ្ឌូនេស៊ីបានបង្ហាញថាពលករនេសាទត្រូវបានគេបង្ខំឲ្យធ្វើការរហូតដល់ ២០ ម៉ោងក្នុងមួយថ្ងៃ។[23] ក្រៅពីធ្វើការរយៈពេលយូរ ពលករមិនមានថ្ងៃឈប់សម្រាកទេ មិនបានទទួលនូវអាហារ ឬប្រាក់ខែគ្រប់គ្រាន់។ ពេលខ្លះពួកគេត្រូវបានរំលោភបំពានដោយប្រធានក្រុមរបស់ពួកគេ។[22] ក៏មានករណីរងរបួស ឬ ការស្លាប់ដែលកើតចេញពីការធ្វើការនៅក្នុងនាវានេសាទផងដែរ។ យោងតាមអង្គការពលកម្មអន្តរជាតិ(ILO) ប្រចាំបាងកកចាប់ពីខែមិថុនា ដល់ ខែតុលា ឆ្នាំ ២០១៤ ប្រជាជនកម្ពុជាជាង ២២.០០០ នាក់បានចុះឈ្មោះចូលធ្វើការនៅក្នុងឧស្សាហកម្មនេសាទនៅក្នុងប្រទេសថៃ។[23]

**ពលកម្មដោយបង្ខំតាមរយៈការងារតាមផ្ទះ៖**ពលកម្មដោយបង្ខំក្នុងការងារតាមផ្ទះគឺជាបទឧក្រិដ្ឋមួយផ្សេងទៀត។ ពលករកម្ពុជាត្រូវបានគេរាយការណ៍ថាត្រូវបានគេជួញដូរទៅប្រទេសម៉ាឡេស៊ី មជ្ឈឹមបូព៌ា និងសិង្ហបុរី ដើម្បីធ្វើការជាអ្នកថែរក្សាកុមារ អ្នកសម្អាតផ្ទះ និង ថែទាំមនុស្សចាស់/អ្នកជំងឺ។ ទោះបីជាពួកគេទទួលបានប្រាក់ខែខ្ពស់ជាងប្រទេសកម្ពុជាបីដងក៏ដោយ ក៏ពលករចំណាកស្រុកទាំងនោះទទួលរងការរំលោភបំពានធ្ងន់ធ្ងរ ហើយត្រូវបានរាយការណ៍ជាញឹកញាប់ថាមានបញ្ហាផ្លូវចិត្តនៅពេលត្រលប់មកផ្ទះវិញ។ នៅឆ្នាំ ២០១៥ មានពលករបម្រើតាមផ្ទះចំនួន ៨.០០០ នាក់កំពុងធ្វើការនៅប្រទេសម៉ាឡេស៊ី។[24]

**ការបង្ខំឲ្យសុំទាន៖** កុមារកម្ពុជាត្រូវបានរាយការណ៍ថាត្រូវបានគេជួញដូរសម្រាប់ឲ្យសុំទាននៅប្រទេសជិតខាងដូចជាប្រទេសថៃ និងវៀតណាម។ ក្នុងឆ្នាំ ២០១៤ ប្រហែល ៨០% នៃកុមារសុំទាននៅក្នុងប្រទេសថៃ គឺជាជនជាតិខ្មែរ។ [25]

**ការជួញដូរ សម្រាប់ផលចំណេញក្នុងការធ្វើអាជីវកម្មផ្លូវភេទ ៖** ស្ត្រីត្រូវបានគេចាត់ទុកថាជាជនរងគ្រោះ តែមួយគត់នៅក្នុងឧស្សាហកម្មផ្លូវភេទ ប៉ុន្តែថ្មីៗនេះក្មេងប្រុស និងបុរសវ័យក្មេងក៏ស្ថិតក្នុងប្រភេទជនរងគ្រោះផងដែរ។ ក្មេងរស់តាមចិញ្ចើមថ្នល់ ជាពិសេសក្មេងប្រុសជារឿយៗត្រូវបានគេស្គាល់ថាជាជនរងគ្រោះនៃការរំលោភបំពានផ្លូវភេទពីជនបរទេស។[16] ក្មេងស្រីវៀតណាមត្រូវបានគេរាយការណ៍ថាត្រូវបានគេជួញដូរទៅផ្ទះបននៅប្រទេសកម្ពុជា។ ទិន្នន័យរបស់ NCCT បានបង្ហាញថាមានជនរងគ្រោះនៃការជួញដូរផ្លូវភេទចំនួន ២៩៨នាក់ដែលត្រូវបានជួយសង្គ្រោះនៅកម្ពុជាក្នុងឆ្នាំ ២០១៦ ហើយកុមារ និងអនីតិជនស្ថិតក្នុងចំណោមជនរងគ្រោះទាំងនោះ។[19]

### *៣.២ មូលហេតុនៃការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ*

ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទបានកើតមានក្នុងលក្ខខណ្ឌចំនួនបី។ ទី១ ភាពក្រីក្រគឺជាមូលហេតុនៃការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ។ យើងបានរកឃើញថាជនរងគ្រោះនៃការជួញដូរមនុស្សជារឿយៗជាមនុស្សដែលក្រីក្រមិនមានចំណេះដឹងខាងបញ្ញា ឬ ជនពិការ ឬ អ្នកដែលមិនមានសុវត្ថិភាព ឬឱកាសសម្រាប់ការរស់នៅគ្រប់គ្រាន់។ អតុល្យភាពសេដ្ឋកិច្ច-សង្គមបានឲ្យក្រុមមួយចំនួនរស់នៅក្នុងស្ថានភាពលំបាកជាងអ្នកដទៃ។ អ្នកជួញដូរជារឿយៗសំដៅទៅលើប្រជាជនទាំងនោះ ហើយឈ្លៀតធ្វើអាជីវកម្មលើពួកគេ។ កុមារ និងស្ត្រីជារឿយៗធ្លាក់ចូលក្នុងប្រភេទនេះ ហើយក្លាយជាជនរងគ្រោះនៃការជួញដូរមនុស្ស។[15, 26]

ទី២ ជនរងគ្រោះនៃការជួញដូរមនុស្សជាញឹកញាប់គឺជាពលករចំណាកស្រុក។ ដោយនិយាយបែបនេះវាមិនមែនមានន័យថាការធ្វើចំណាកស្រុកនាំទៅរកការជួញដូរមនុស្សទេ។ ការស្រាវជ្រាវបានបង្ហាញពីកត្តាដែលនាំឲ្យពលករចំណាកស្រុកក្លាយទៅជាជនរងគ្រោះនៃការជួញដូរមនុស្សគឺ៖ i) ការធ្វើចំណាកស្រុកខុសច្បាប់ ii)ការបោកបញ្ឆោតរបស់ឈ្មួញកណ្តាល ឬ អ្នកជួញដូរ iii) ការខ្វះព័ត៌មានអំពីការងារ និងទីកន្លែងដែលត្រូវធ្វើការ និង iv) ការខ្វះវិធានការការពារ ឬ ប្រព័ន្ធគាំទ្រដល់ពលករចំណាកស្រុក។ [22, 26]

ទី៣ ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ គឺជាអាជីវកម្មដែលផ្តល់ចំណេញច្រើន ហើយត្រូវបានដំណើរការដោយផ្អែកលើគោលការណ៍នៃការផ្គត់ផ្គង់ និងតម្រូវការ។ នៅពេលដែលមានតម្រូវការ វានឹងមានក្រុមឈ្មួញកណ្តាលដែលព្យាយាមរកផលចំណេញ តាមរយៈការស្វែងរកកម្លាំងពលកម្មថោក

ដើម្បីបំពេញនូវការផ្គត់ផ្គង់។ នេះទំនងជាមានន័យថា មនុស្សត្រូវបានគេជួញដូរទៅកន្លែងអ្នកមានច្រើនជាងទៅកន្លែងក្រីក្រ។[26] ការទប់ស្កាត់តម្រូវការការជួញដូរមនុស្ស អាចកាត់បន្ថយហានិភ័យនៃអំពើជួញដូរមនុស្ស។

### *៣.៣ ការបង្កាទប់ស្កាត់ ការអនុវត្តច្បាប់ និងកិច្ចការពារ*

រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងជាច្រើនដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៩០។ រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើពិធីសារ [iii] និងអនុសញ្ញាអន្តរជាតិ[iv] ព្រមទាំងបានផ្តល់សច្ចាប័ន[v] លើច្បាប់ប្រឆាំងនឹងការជួញដូរមនុស្ស។ រាជរដ្ឋាភិបាលកម្ពុជាក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីជាមួយបណ្តាប្រទេសមួយចំនួនក្នុងតំបន់ដូចជាកិច្ចព្រមព្រៀងទ្វេភាគីជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម និងរាជរដ្ឋាភិបាលថៃស្តីពីកិច្ចសហប្រតិបត្តិការដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។ រដ្ឋាភិបាលក៏បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់ពហុភាគីប្រឆាំងនឹងការជួញដូរមនុស្សនៅក្នុងមហាអនុតំបន់មេគង្គ និងសន្ធិសញ្ញាស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងបញ្ហាព្រហ្មទណ្ឌក្នុងចំណោមបណ្តាប្រទេសអាស៊ាន។ [27]

ប្រទេសកម្ពុជាក៏បានបង្កើតផងដែរនូវស្ថាប័នរដ្ឋាភិបាលរបស់ខ្លួនដើម្បីទទួលខុសត្រូវចំពោះសកម្មភាពប្រឆាំងការជួញដូរមនុស្ស។ គណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស (NCCT) គឺជាអ្នកទទួលខុសត្រូវ ដ៏សំខាន់របស់រដ្ឋាភិបាលក្នុងការជំរុញការអនុវត្តច្បាប់ និងត្រួតពិនិត្យការងារពាក់ព័ន្ធនឹងការជួញដូរមនុស្ស។ NCCTត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងមានរចនាសម្ព័ន្ធរបស់ខ្លួននៅតាមកម្រិតថ្នាក់ក្រោមជាតិ ។[28] NCCT ក៏មានក្រសួងចំនួន ៤ ជាសមាជិកផងដែរ។ សកម្មភាពសំខាន់ៗរបស់ NCCT រហូតមកដល់ពេលនេះរួមមាន៖ i) ការបង្កើតគោលនយោបាយជាតិ និងកិច្ចសហប្រតិបត្តិការអន្តរជាតិដែលទាក់ទងនឹងការជួញដូរមនុស្ស ii) ការទប់ស្កាត់បទល្មើសការជួញដូរ តាមរយៈការអប់រំ និងលើកកម្ពស់ការយល់ដឹងរបស់ជនចំណាកស្រុកតាមរយៈប្រព័ន្ធផ្សព្វផ្សាយ វេទិកាសាធារណៈ បច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា (ICT) និងវគ្គបណ្តុះបណ្តាល iii) ការអនុវត្តច្បាប់ និងការដាក់ទោសដល់ជនល្មើសជួញដូរមនុស្ស និង iv) ផ្តល់កិច្ចការពារដល់ជនរងគ្រោះ។[19]

---

[iii] ពិធីសារអង្គការសហប្រជាជាតិដើម្បីបង្ការ ទប់ស្កាត់ និងដាក់ទណ្ឌកម្មដល់ការជួញដូរមនុស្ស

[iv] អនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មបរទេស អនុសញ្ញាស្តីពីសិទ្ធិស៊ីវិល និងនយោបាយ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW) និងអនុសញ្ញាស្តីពីសិទ្ធិកុមារ

[v] ច្បាប់ស្តីពីការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ ដែលបានអនុម័តឆ្នាំ២០០៥ ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ដែលបានអនុម័តឆ្នាំ ២០០៨ និងច្បាប់យុត្តិធម៌សម្រាប់អនីតិជន ដែលបានអនុម័តឆ្នាំ ២០១៦។

អង្គការមិនមែនរដ្ឋាភិបាលក៏បានដើរតួយ៉ាងសំខាន់ក្នុងការដោះស្រាយការជួញដូរមនុស្ស នៅកម្ពុ-ជា ជាពិសេសទាក់ទងនឹងសេវាបង្កាទប់ស្កាត់ និងការពារ។ ឧទាហរណ៍ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (Cambodia's Women Crisis Center: CCWC)បានអនុវត្តកម្មវិធីចំណាកស្រុកប្រកបដោយសុវត្ថិភាពដើម្បីចែករំលែកព័ត៌មានដល់ពលករចំណាកស្រុក។[22] អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី (Legal Support for Children and Women: LSCW) និងអង្គការខារ៉ាមកម្ពុជា (Coordination of Action Research on AIDS and Mobility: CARAM) ផ្តល់នូវបណ្តាញទូរស័ព្ទបន្ទាន់សម្រាប់ជំនួយប្រឹក្សា និងសេវាធ្វើមាតុភូមិនិវត្តន៍។[22] អង្គការក្រៅរដ្ឋាភិបាលដទៃទៀត[ឧ. អង្គការពន្លកថ្មី( Punlork Thmey) អង្គការបញ្ឈប់ការជួញដូរកុមារកម្ពុជា (The Cambodia Against Child Trafficking: ACTs) អង្គការសង្ឃឹមសម្រាប់យុត្តិធម៌(Hope for Justice)] បានផ្តល់សេវាបង្ការទប់ស្កាត់ និងការគាំទ្ររួមបញ្ចូលទាំងការបណ្តុះបណ្តាលជំនាញដល់ជនរងគ្រោះ។[19]

ទោះបីជាមានការខិតខំប្រឹងប្រែងទាំងនេះក៏ដោយ ក៏នៅមានចន្លោះប្រហោង និងបញ្ហាប្រឈមក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទនៅក្នុងប្រទេសកម្ពុជា។ ទី១ ការស្រាវជ្រាវបានបង្ហាញថាកម្រិតនៃការអនុវត្តច្បាប់ ការប្តឹងចោទប្រកាន់ និងការដាក់ទោសលើការជួញដូរមនុស្សនៅមានកម្រិតនៅឡើយ ជាពិសេសចំពោះករណីស្មុគស្មាញដែលពាក់ព័ន្ធនឹងការជួញដូរឆ្លងដែន។[15] នេះគឺដោយសារតែការប្តឹងចោទប្រកាន់នៅក្នុងករណីជួញដូរមានភាពលំបាកដោយសារតែជនរងគ្រោះមិនបានដឹងពីអត្តសញ្ញាណរបស់ឈ្មួញកណ្តាល ឬអ្នកជួញដូរ អាស័យដ្ឋាន ឬ រោងចក្រដែលបទល្មើសបានកើតឡើង។ កង្វះភស្តុតាងជាក់ស្តែង ឬ ការខ្វះព័ត៌មានដើម្បីកសាងសំណុំរឿងដ៏រឹងមាំគឺជាហេតុផលមួយទៀត។[22] ទី២ទោះបីជាមានការរីកចម្រើនខ្លះៗលើកិច្ចការពារជនរងគ្រោះក៏ដោយ ក៏រាជរដ្ឋាភិបាលនៅតែពឹងផ្អែកលើអង្គការក្រៅរដ្ឋាភិបាលដើម្បីធ្វើសេវាកម្ម ហើយនៅក្នុងកាលៈទេសៈជាច្រើនរដ្ឋាភិបាលមិនបានផ្តល់ជំនួយឲ្យបានគ្រប់គ្រាន់ដល់អង្គការក្រៅរដ្ឋាភិបាល ដើម្បីឲ្យពួកគេអាចធ្វើការងារឲ្យមានប្រសិទ្ធភាពនោះទេ។[15] ទី៣ ថវិកាសម្រាប់បេសកកម្មការទូតកម្ពុជានៅក្រៅប្រទេសនៅតែមិនមានគ្រប់គ្រាន់ និងសមត្ថភាពក្នុងការផ្តល់ជំនួយដល់ជនរងគ្រោះដែលត្រូវបានបញ្ជូនត្រឡប់មកវិញក៏មិនទាន់មានគ្រប់គ្រាន់។ ក្នុងករណីមួយចំនួនពលករត្រូវបានគេកំណត់អត្តសញ្ញាណនៅក្នុងប្រទេសដែលមិនមានតំណាងការទូតកម្ពុជា ហេតុដូច្នេះពួកគេមិនបានទទួលការគាំទ្រណាមួយសម្រាប់ការការពារទាល់តែសោះ។[15] ទី៤ ទោះជាមានកិច្ចខិតខំប្រឹងប្រែងមួយចំនួនដើម្បីទប់ស្កាត់ការជួញដូរមនុស្សតាមរយៈកម្មវិធីអន្តោប្រវេសន៍ប្រកបដោយសុវត្ថិភាពក៏ដោយ ពលករជាច្រើននៅតែបន្តធ្វើចំណាកស្រុកដោយខុសច្បាប់។ ការអប់រំ និងការផ្តល់ព័ត៌មានអំពីការធ្វើចំណាកស្រុកដែលមានសុវត្ថិភាពមិនគ្រប់គ្រាន់ទេ។ វាចាំបាច់គួរមានការគាំទ្របន្ថែមទៀតលើការកសាងសុវត្ថិភាពជីវភាពរស់នៅរបស់ប្រជាជនក្នុងប្រទេស ជាពិសេសក្នុងចំណោមជនរងគ្រោះដែលត្រូវបានបញ្ជូនត្រឡប់មកវិញ។ [22]

## ៣.៤ សំនួរគន្លឹះសម្រាប់កម្រងសំនួរ

សំណួរជាក់លាក់ដើម្បីតាមដានពីវឌ្ឍនភាពក្នុងការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទមានដូចខាងក្រោម៖

- តើអ្នកណាជាជនរងគ្រោះនៃការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទនៅក្នុងតំបន់របស់អ្នក?
- តើមានកត្តាជំរុញអ្វីខ្លះដែលធ្វើឲ្យប្រជាជនក្លាយទៅជាជនរងគ្រោះនៃការជួញដូរមនុស្ស?
- តើវិស័យណាខ្លះដែលពាក់ព័ន្ធនឹងការជួញដូរមនុស្ស?
- តើមានកំណត់ត្រាគ្រប់គ្រាន់ស្ដីពីទិន្ន័យនៃការធ្វើចំណាកស្រុក និងការជួញដូរមនុស្សនៅក្នុងតំបន់របស់អ្នកដែរឬទេ? តើកំណត់ត្រានោះត្រូវបានកត់ត្រាជាទៀងទាត់ដែរឬទេ?
- តើមានអ្វីខ្លះដែលបានធ្វើរួចមកហើយទៅលើការទប់ស្កាត់ ការអនុវត្តច្បាប់ និងកិច្ចការពារពាក់ព័ន្ធនឹងការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទនៅក្នុងតំបន់របស់អ្នក?
  - តើការទប់ស្កាត់ប្រភេទណាខ្លះដែលធ្វើនៅក្នុងតំបន់របស់អ្នក? តើអ្នកណាដែលធ្វើវា? តើពួកគេធ្វើយ៉ាងម៉េច? តើវាមានប្រសិទ្ធភាពយ៉ាងណាដែរ?
  - តើការអនុវត្តច្បាប់បែបណាខ្លះដែលបានធ្វើកន្លងមក? តើអ្នកណាពាក់ព័ន្ធនឹងការងារអនុវត្តច្បាប់នេះ? តើពួកគេធ្វើយ៉ាងម៉េច? តើមានបទល្មើសជួញដូរមនុស្ស និងផ្លូវភេទប៉ុន្មាននាក់ត្រូវបានផ្តន្ទាទោស? តើវាមានប្រសិទ្ធភាពយ៉ាងណាដែរ?
  - តើមានសេវាកម្មការពារប្រភេទណាខ្លះដែលបានផ្តល់ដល់ជនរងគ្រោះនៃការជួញដូរមនុស្ស?តើអ្នកណាដែលធ្វើវា? ពួកគេធ្វើយ៉ាងម៉េច? តើវាមានប្រសិទ្ធភាពយ៉ាងណាដែរ?
- តើតួនាទីរបស់អង្គការក្រៅរដ្ឋាភិបាលក្នុងការទប់ស្កាត់ ការអនុវត្តច្បាប់ និងកិច្ចការពារការជួញដូរមនុស្សនៅក្នុងតំបន់របស់អ្នកមានអ្វីខ្លះ?
- តើមានបញ្ហាប្រឈម ឬ ឧបសគ្គអ្វីខ្លះលើការងារទប់ស្កាត់ ការអនុវត្តច្បាប់ និងកិច្ចការពារនៅក្នុងតំបន់របស់អ្នក?
- តើអ្វីខ្លះដែលអាចធ្វើទៅបានដើម្បីកែលម្អស្ថានភាពនេះ?

## ៤. សេចក្តីសន្និដ្ឋាន

ការធ្វើចំណាកស្រុក ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ នៅតែជាបញ្ហាសំខាន់សម្រាប់រាជរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធគោលនយោបាយ និងការអនុវត្តច្បាប់។ ការធ្វើចំណាកស្រុក និងការជួញដូរមនុស្សគឺពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធ ដែលបង្កឡើងដោយសារភាពក្រីក្រ។ មនុស្សជាច្រើនបានចាត់ទុកថាការធ្វើចំណាកស្រុកជាមធ្យោបាយដើម្បីលើកកម្ពស់ការចិញ្ចឹមជីវិតរបស់ខ្លួន និងដើម្បីគេចចេញពីភាពក្រីក្រ។ បើតាមការប៉ាន់ប្រមាណមានកម្លាំងពលកម្មវ័យក្មេងចំនួន ៣០.០០០នាក់ ដែលភាគច្រើនពួកគេខ្វះជំនាញ ចំនុចនេះមានន័យថាកម្ពុជាកំពុងជួបបញ្ហាក្នុងការបង្កើតឱកាសការងារឲ្យបានគ្រប់គ្រាន់សម្រាប់ពួកគេ។ ជាលទ្ធផល វាអាចបង្ហាញថាការធ្វើចំណាកស្រុកនឹងមានការកើនឡើង។ ផលប៉ះពាល់ពីការធ្វើចំណាកស្រុកមានច្រើនយ៉ាង។ ដោយទំហំប្រាក់បញ្ញើរពីបរទេសមានកាន់តែច្រើន និងកើនឡើង វាច្បាស់ណាស់ដែរថាការធ្វើចំណាកស្រុកអាចជួយលើកកំពស់កម្រិតជីវភាពរបស់គ្រួសារមួយចំនួនឲ្យចាកផុតពីភាពក្រីក្រ។ តែទោះយ៉ាងណាក៏ដោយ ការធ្វើចំណាកស្រុក ជាពិសេសចំណាកស្រុកខុសច្បាប់បានធ្វើឲ្យប្រជាជនធ្លាក់ទៅក្នុងស្ថានភាពងាយទទួលរងគ្រោះ និងការរំលោភបំពានផងដែរ។ តាមរយៈឯកសារស្រាវជ្រាវបានបង្ហាញថា ការធ្វើចំណាកស្រុកដោយមានឯកសារស្របច្បាប់អាចជម្រុញឲ្យមានផលប៉ះពាល់វិជ្ជមាន និងធានាសុវត្ថិភាពដល់ជនចំណាកស្រុក។ ប៉ុន្តែ ការចំណាយពេលលើដំណើរការ និងការចំណាយខ្ពស់ពាក់ព័ន្ធនឹងការរៀបចំឯកសារ អាចមិនលើកទឹកចិត្តឲ្យប្រជាជនធ្វើការចំណាកស្រុកស្របច្បាប់ឡើយ។

ពលករចំណាកស្រុក ជាពិសេសពលករខុសច្បាប់ អាចងាយទទួលរងគ្រោះនឹងបញ្ហាជួញដូរមនុស្ស។ ប្រទេសកម្ពុជានៅតែជាប្រភព កន្លែងឆ្លងកាត់ ហើយនឹងជាគោលដៅសម្រាប់ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ។ ការរយៈឯកសារស្រាវជ្រាវ ទាសភាពសម័យទំនើប និងការជួញដូរមនុស្សនៅក្នុងប្រទេសកម្ពុជាមានពាក់ព័ន្ធនឹងវិស័យសំខាន់ៗមួយចំនួនដូចជា៖ ផលិតកម្ម ការដាំដុះ សំណង់ និងការងារតាមផ្ទះ។ នៅក្រៅប្រទេសកម្ពុជា ការជួញដូរមនុស្សកើតមានច្រើនរូបភាពដូចជា៖ ១) ការជួញដូរតាមរយៈការរៀបអាពាហ៍ពិពាហ៍ ២) ពលកម្មដោយបង្ខំលើនាវានេសាទ ៣) ពលកម្មដោយបង្ខំតាមរយៈការងារតាមផ្ទះ ៤) ការបង្ខំឲ្យសុំទាន និង ៥) ការជួញដូរសម្រាប់ផលចំណេញក្នុងការធ្វើអាជីវកម្មផ្លូវភេទ។

រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានាបានអនុវត្តកិច្ចខិតខំប្រឹងប្រែងជាច្រើនដើម្បីទប់ស្កាត់ការជួញដូរមនុស្ស និងលើកកម្ពស់ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងស្របច្បាប់។ កិច្ចខិតខំប្រឹងប្រែងទាំងនោះរួមមានការអនុវត្ត និងការធ្វើបច្ចុប្បន្នភាពគោលនយោបាយជាតិ ការអនុវត្តតាមពិធីសាអន្តរជាតិ

ការចុះអនុស្សរណៈយោគយល់ ការចុះអនុសញ្ញា និងច្បាប់នានា។ មានជម្រើសគោលនយោបាយជាតិមួយចំនួនដែលត្រូវពិចារណា៖

- ការដោះស្រាយការធ្វើចំណាកស្រុកខុសច្បាប់ និងការជួញដូរមនុស្ស គួរត្រូវបានអនុវត្តនៅចំនុចឬសគល់របស់វាគឺភាពក្រីក្រ។ ដូច្នេះ ការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច ការលើកកម្ពស់ផលិតភាពកសិកម្ម និងការលើកកម្ពស់ការទទួលបានសេវាសង្គមគឺមានសារៈសំខាន់។
- ដោយសារពលករចំណាកស្រុកខុសច្បាប់អាចងាយនឹងទទួលរងការរំលោភបំពាន និងការជួញដូរ យន្តការលើកកម្ពស់ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពនឹងអាចជួយកាត់បន្ថយហានិភ័យទាំងអស់នេះបាន។ យន្តការទាំងនោះអាចរួមមាន៖ (១) កាត់បន្ថយការចំណាយ និងដំណើរការនៃការរៀបចំធ្វើឯកសារសម្រាប់អ្នកចំណាកស្រុកក្រីក្រ (២) ផ្សព្វផ្សាយការធ្វើចំណាកសុកប្រកបដោយសុវត្ថិភាពតាមរយៈយុទ្ធនាការអប់រំ។
- ដោយសាយការជួញដូរមនុស្សនៅតែជាបញ្ហាប្រឈមសំខាន់មួយ វាចាំបាច់ត្រូវពង្រឹងការអនុវត្តយន្តការច្បាប់ដែលមានដើម្បីការពារពលករចំណាកស្រុក ដែលក្នុងនោះរួមមានច្បាប់នានាដែលមាន អនុសញ្ញាអន្តរជាតិ និងការចុះអនុស្សរណៈយោគយល់។

## ឯកសារយោង


1. Barwitzki S (2014). Migration and Human Trafficking: The case of Cambodia. Phnom Penh, Cambodia: Heinrich Boll Foundation.
2. ILO (2016). Triangle II Quarterly Briefin Note. Bangkok, Thailand: International Labour Orgnisation.
3. MOLVT (2014). Policy on Labour Migration for Cambodia. Phnom Penh, Cambodia Ministry of Labour and Vocational Training.
4. Hing Vutha, PIde, L. & DAlis, P. (2011). Irregular Migration: Characteristics, Challenges and Policy Responses. *Working Paper 58.* Phnom Penh: CDRI.
5. Maltoni B (2007). Migration in Cambodia: Internal vs. External Flows. Phnom Penh, Cambodia: International Organisation for Migration.
6. MOLVT (2017). Annual Report 2016-2017. Phnom Penh, Cambodia: Ministry of Labour and Vocational Training
7. Dickson, B. & Koenig, A. (2016). Assessment Report: Profile of Returned Cambodia Migrant Worker. International Organisation for Migration (IOM) Cambodia.
8. Sophal Chan (2009). Review of Labour Migration Management Policies and Legal Framework in Cambodia. Bangkok, Thailand: ILO Regional Office for Asia and the Pacific.
9. Diepart JC (2016). They Will Need Land! The Current Land Tenure Situation an dFuture Land Allocation for Smallholder Farmers in Cambodia. Vientiane, Lao PDR: Mekong Region Land Governance.
10. CDRI (2009). Costs and Benefits of Cross-country Labour Migration in the GMS: Synthesis of the CAse Studies in Cambodia, Laos, Thailand and Vietnam. *Working Paper 45.* Phnom Penh: CDRI.

11. Kimsun Song (2012). Migration, remittances and poverty reduction: Evidence from Cambodia. *CDRI Cambodia Development Review,* 15, 7-12.
12. Roth, V., Hing, V., Phann, D. & Sum, S. (2015). Effects of Emigration and Remittances on the Left-Behind: The Case of Cambodia. *Interim Report.* Phnom Penh, Cambodia: CDRI.
13. Vutha, H., Pide, L. & Dalis, P. (2014). The Impacts of Adult Migration on Children´s Well-being The Case of Cambodia. Phnom Penh: CDRI.
14. Lim, S. (2007). Youth Migration and Urbanisation in Cambodia. *CDRI Working Paper 36.* Phnom Penh, Cambodia: CDRI.
15. USDepartmentofState (June 2016). Trafficking in persons report US: US Department of State.
16. TheMinderooFoundation (2016). The Global Slavery Index 2016. India: The Minderoo Foundation Pty Ltd.
17. Walk Free Foundation Survey Data (2015). Gallup World Poll.
18. InternationalJusticeMission (2016). Labor Trafficking in Cambodia: A Review of the Public Justice System's Response Washington DC: International Justice Mission.
19. NationalCommitteeforCounterTrafficking (2016). Summary Report on Results of Counter Trafficking in 2016.
20. USDepartmentofState (2013). Trafficking in Persons Report - Cambodia US: US Department of State.
21. Hong, L. S. (2016). *Cross-Border Labor Migration Surges in Cambodia, Raising Risk of Human Trafficking* [Online].
22. Burnett, N. (2015). Cambodia's Invisible Labor Force: Does Safe Migration Prevent Human Trafficking? Phnom Penh: Heinrich Böll Foundation.
23. InterationalOrganizationforMigration (2016). Report on Human Trafficking, Forced Labour and Fisheries Crime in the Indonesian Fishing Industry. Jarkata: IOM.
24. Titthara, M. & Cudd, A. (2015). The Shackles Of Abuse. *The Phnom Penh Post*, September 26, 2015.

25. Yongcharoenchai, C. (2014). Young Lives for Sale *Bangkok Post*, June 29, 2014.
26. AlexandraBarwitzki, S. (2014). Migration and Human Trafficking: The Case of Cambodia. Phnom Penh: Heinrich Böll Foundation.
27. NationalCommitteeforCounterTrafficking (2015). National Plan of Action of the National Committee for Counter Trafficking. Phnom Penh: NCCT.
28. NationalCommitteeforCounterTrafficking. (2017). *National Committee for Countering Trafficking: About Us* [Online]. Available: http://www.ncct.gov.kh/en/about-us [Accessed 20 July 2017 2017].